# ក្របខណ្ឌភាពជាដៃគូសម្រាប់ប្រទេសកម្ពុជា (CPF) ២០១៩-២០២៣

*សេចក្តីសង្ខេបនៃការពិគ្រោះយោបល់តាមប្រព័ន្ធអនឡាញ*

ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៩

<u>អ្នកឆ្លើយសំណួរ៖</u> ១១នាក់ បានឆ្លើយសំណួរក្នុងការស្ទង់មតិជាភាសាអង់គ្លេស និង ៧នាក់ ក្នុងការស្ទង់មតិជាភាសាខ្មែរ។

<u>សេចក្តីផ្តើម៖</u> ការស្ទង់មតិអនឡាញ—ទាំងជាភាសាខ្មែរ ទាំងជាភាសាអង់គ្លេស—ត្រូវបានផុស្តលើវេបសាយរបស់ធនាគារពិភពលោក ដើម្បីប្រមូលទស្សនៈយល់ឃើញរបស់សាធារណជនថាតើ ធនាគារពិភពលោកអាចធ្វើដូចម្តេចខ្លះដើម្បីឱ្យបានផលច្រើនបំផុតទៅលើការអភិវឌ្ឍរបស់ប្រទេសកម្ពុជា។

***តើធនាគារពិភពលោកអាចធ្វើដូចម្តេចខ្លះដើម្បីឱ្យបានផលច្រើនបំផុតទៅលើការអភិវឌ្ឍរបស់ប្រទេសកម្ពុជា?***

*បណ្តាផ្នែកដែលគេបានជ្រើសរើសនៅខាងក្រោម ត្រូវបានរៀបរៀងទៅតាមចំនួនអ្នកឆ្លើយពីច្រើនបំផុតរហូតដល់តិចបំផុត សម្រាប់ជម្រើសនីមួយៗ។*

- កិច្ចគាំពារសង្គម និងសំណាញ់សុវត្ថិភាព
- បង្កើតការងារ
- កែលម្អគុណភាពអប់រំឱ្យប្រសើរ
- លទ្ធភាពរកបានហិរញ្ញប្បទាន
- កាត់បន្ថយភាពក្រីក្រ និងវិសមភាព
- កែលម្អការផ្តល់សេវាសាធារណៈឱ្យប្រសើរ
- កសិកម្ម និងសន្តិសុខស្បៀង
- បង្កើនប្រសិទ្ធផលរបស់វិស័យអភិបាលកិច្ច និងរបស់វិស័យសាធារណៈ
- កែលម្អគុណភាពសេវាសុខាភិបាល និងអាហារូបត្ថម្ភឱ្យប្រសើរ
- ការអភិវឌ្ឍជនបទ
- ភាពធន់ទ្រាំនឹងគ្រោះមហន្តរាយ ការប្រែប្រួលអាកាសធាតុ ចីរភាពបរិស្ថាន
- ការធ្វើពាណិជ្ជកម្ម

- ការចូលរួមរបស់ពលរដ្ឋ ការបញ្ចេញយោបល់របស់ពលរដ្ឋ និងគណនេយ្យភាពសង្គម
- កិច្ចសហប្រតិបត្តិការក្នុងតំបន់ និងលើសកលលោក
- ទឹក និងអនាម័យ
- គមនាគមន៍ដឹកជញ្ជូន បច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍
- ការអភិវឌ្ឍនគរូបនីយកម្ម

*ក្នុងទស្សនៈរបស់អ្នក តើផ្នែកណាខ្លះក្នុងចំណោមចំណុចខាងក្រោម ដែលនឹងរួមចំណែកខ្លាំងជាងគេដល់ការកែលម្អកាន់តែប្រសើរនូវប្រសិទ្ធផលការងាររបស់រដ្ឋាភិបាលនៅក្នុងការផ្តល់សេវាដល់ពលរដ្ឋ និងនៅក្នុងការលើកកម្ពស់ការអភិវឌ្ឍផ្នែកឯកជន ?*

*បណ្តាផ្នែកដែលគេបានជ្រើសរើសនៅខាងក្រោម ត្រូវបានរៀបរៀងទៅតាមចំនួនអ្នកឆ្លើយពីច្រើនបំផុតរហូតដល់តិចបំផុត សម្រាប់ជម្រើសនីមួយៗ។*

- ផ្តល់ការគាំទ្រដល់សហគ្រាសខ្នាតតូចនិងមធ្យម (SMEs)
- ជំរុញទៅមុខនូវកំណែទម្រង់រដ្ឋបាលសាធារណៈ និងពង្រឹងការផ្តល់សេវាសាធារណៈ
- ពង្រីក និងកែលម្អសេវាហេដ្ឋារចនាសម្ព័ន្ធប្រកបដោយចីរភាពកាន់តែប្រសើរឡើង
- ជំរុញទៅមុខនូវដំណើរការវិមជ្ឈការ និងពង្រឹងសមត្ថភាពរដ្ឋាភិបាលថ្នាក់មូលដ្ឋាន
- បង្កើនភាពបរិយាប័ន្នផ្នែកហិរញ្ញវត្ថុ ជាពិសេសសម្រាប់ស្ត្រី
- បង្កើតឱ្យមានកម្មវិធីកសាងជំនាញឱ្យចំគោលដៅសម្រាប់យុវជននិងក្រុមពលរដ្ឋផ្សេងទៀត
- ពង្រឹងគណនេយ្យភាពផ្នែកសាធារណៈ និងហិរញ្ញវត្ថុសាធារណៈ
- ធ្វើឱ្យបរិស្ថានធុរកិច្ចកាន់តែមានភាពប្រសើរដើម្បីបង្កើនភាពប្រកួតប្រជែង
- ពង្រឹងពង្រីកការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ
- បង្កើតឱ្យមានកម្មវិធីកសាងជំនាញឱ្យចំគោលដៅសម្រាប់យុវជននិងក្រុមពលរដ្ឋផ្សេងទៀត
- គាំទ្រដល់ការធ្វើអន្តរកាលឆ្ពោះទៅកាន់សេដ្ឋកិច្ចតាមប្រព័ន្ធឌីជីថល
- លើកកម្ពស់ឱ្យមានការអនុវត្តផ្នែកពាណិជ្ជកម្មមានប្រសិទ្ធផល ( ដំណើរការគយ ចំណាត់ការឯកសារ ជាដើម...) ដើម្បីកាត់បន្ថយចំណាយថ្លៃដើមរបស់ផ្នែកឯកជន
- បង្កើតប្រព័ន្ធអេកូឡូស៊ីមួយដើម្បីជំរុញឱ្យមាននវានុវត្តន៍

*កែលម្អគុណភាពអប់រំឱ្យប្រសើរ*

*បណ្តាផ្នែកដែលគេបានជ្រើសរើសនៅខាងក្រោម ត្រូវបានរៀបរៀងទៅតាមចំនួនអ្នកឆ្លើយពីច្រើនបំផុតរហូតដល់តិចបំផុត សម្រាប់ជម្រើសនីមួយៗ។*

- ដាក់ចេញដំណើរការវិមជ្ឈការដើម្បីបង្កើតស្វ័យភាពផ្នែកគ្រប់គ្រងឱ្យកាន់តែធំជាងមុននៅថ្នាក់ខេត្ត ថ្នាក់ស្រុក និងនៅកម្រិតសាលារៀន
- រៀបចំបង្កើតគោលនយោបាយប្រកបដោយចីរភាពដើម្បីធ្វើទំនើបកម្មការគ្រប់គ្រងវិស័យអប់រំ
- បង្កើនលទ្ធភាពទទួលបានការអប់រំប្រកបដោយសមធម៌និងមានគុណភាព ដើម្បីឆ្លើយតបទៅនឹងការក្រចូលរៀន និងដើម្បីកាត់បន្ថយអត្រានៃការឈប់រៀន
- ផ្តល់ឱកាសរៀនសូត្រមួយជីវិតដល់គ្រូបង្រៀន
- ដាក់ព័ត៌មានបំពេញកិច្ចផ្នែកអប់រំ និងអំពីថវិកាឱ្យមានជាសាធារណៈ និងពង្រឹងប្រព័ន្ធទទួលមតិយោបល់តបពីសហគមន៍ឬពីមាតាបិតាសិស្ស
- ពង្រីកលទ្ធភាពទទួលបានការអប់រំរបស់កុមារតូច
- ពង្រីកការគ្រប់គ្រងផ្អែកតាមស្ថានភាពសាលាឱ្យទៅដល់សាលារៀនទាំងអស់
- ពង្រឹងការគ្រប់គ្រងស្ថាប័ន និងគណនេយ្យភាពរបស់ការអប់រំថ្នាក់ឧត្តមសិក្សា
- កាត់បន្ថយការបង់សោហ៊ុយក្រៅផ្លូវការនៅតាមសាលារៀន
- ពង្រីកលទ្ធភាពទទួលបានការអប់រំរបស់កុមារតូច
- បន្ថយចំនួនសិស្សរៀនតាមថ្នាក់នីមួយៗ

*កែលម្អគុណភាពសេវាសុខាភិបាល*

*បណ្តាផ្នែកដែលគេបានជ្រើសរើសនៅខាងក្រោម ត្រូវបានរៀបរៀងទៅតាមចំនួនអ្នកឆ្លើយពីច្រើនបំផុតរហូតដល់តិចបំផុត សម្រាប់ជម្រើសនីមួយៗ។*

- ពង្រីកចំណេះដឹង និងសមត្ថភាពរបស់អ្នកអាជីពសុខាភិបាល
- លុបបំបាត់ឱសថក្លែងក្លាយ ឬមានគុណភាពអន់
- ផ្ទេរបុគ្គលិកពេទ្យមានគុណវុឌ្ឍិច្រើននាក់ថែមទៀតឱ្យទៅថ្នាក់ក្រោមជាតិ ជាពិសេសឱ្យទៅបម្រើការនៅតាមមណ្ឌលថែទាំសុខភាពនៅតាមទីជនបទដាច់ស្រយាល
- ធានាយ៉ាងណាឱ្យមានការផ្គត់ផ្គង់ឱសថគ្រប់គ្រាន់នៅតាមមន្ទីរសុខាភិបាលសាធារណៈ
- ដាក់ព័ត៌មានបំពេញកិច្ចរបស់សេវាសុខាភិបាល និងអំពីថវិកាឱ្យមានជាសាធារណៈ និងពង្រឹងប្រព័ន្ធទទួលមតិយោបល់តបពីសហគមន៍ ឬពីអ្នកជំងឺ
- ធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធ និងបរិក្ខារនៅតាមមណ្ឌលថែទាំសុខភាព ឬមន្ទីរពេទ្យ
- កាន់បន្ថយភាពក្រិនដោយបង្កើនការផ្តោតយកចិត្តទុកដាក់លើអាហារូបត្ថម្ភ
- លុបបំបាត់អ្នកផ្តល់សេវាថែទាំសុខភាពឯកជនដែលមិនបានចុះបញ្ជី ឬដែលគ្មានគុណវុឌ្ឍិត្រឹមត្រូវ

*កែលម្អវិស័យកសិកម្មឱ្យប្រសើរ*

*បណ្ដាផ្នែកដែលគេបានជ្រើសរើសនៅខាងក្រោម ត្រូវបានរៀបរៀងទៅតាមចំនួនអ្នកឆ្លើយពីច្រើនបំផុត រហូតដល់តិចបំផុត សម្រាប់ជម្រើសនីមួយៗ។*

- លើកកម្ពស់ការរៀបចំឱ្យមានអង្គការរបស់កសិករ
- ផ្ដល់ការគាំពារដល់កសិករខ្នាតតូចដើម្បីឱ្យគេអាចពង្រីកផលិតភាព និងលទ្ធភាពនាំផលិតផលទៅកាន់ទីផ្សារដើម្បីបង្កើនចំណូល
- លទ្ធភាពទទួលបានប្រព័ន្ធស្រោចស្រពទឹកកាន់តែប្រសើរជាងមុន
- បង្កើនការផ្ដល់ហេដ្ឋារចនាសម្ព័ន្ធ (ផ្លូវ អគ្គិសនី ជាដើម) នៅតាមទីជនបទ
- លទ្ធភាពទទួលបានកាន់តែប្រសើរឡើងនូវធាតុចូលមានគុណភាព (ដូចជា គ្រាប់ពូជ ជី បច្ចេកទេសការពារដំណាំ ជាដើម)
- ផ្ដល់ការគាំពារដល់កសិករខ្នាតតូចដើម្បីឱ្យគេអាចពង្រីកផលិតភាព និងលទ្ធភាពនាំផលិតផលទៅកាន់ទីផ្សារដើម្បីបង្កើនចំណូល
- ផលិតកម្មកសិកម្មកាន់តែមានភាពចម្រុះជាងមុន
- បញ្ច្រាបប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍ទំនើបទៅក្នុងប្រព័ន្ធជាំដុះនៅកម្ពុជា
- បង្កើនលទ្ធភាពទទួលបានសេវាការផ្សព្វផ្សាយកសិកម្មសាធារណៈ
- កែលម្អប្រព័ន្ធផ្លូវ និងប្រព័ន្ធតភ្ជាប់រវាងបណ្ដាញគមនាគមន៍ដឹកជញ្ជូន
- ពង្រីកវិស័យកសិធុរកិច្ចក្នុងប្រទេស
- ធ្វើឱ្យការផ្គត់ផ្គង់ទឹកកាន់តែមានភាពប្រសើរឡើង
- បង្វែរទិសទៅបង្កើតប្រព័ន្ធផលិតកម្មកសិកម្មសរីរាង្គ(បញ្ជាក់ដោយវិញ្ញាបនបត្រ)

***ធ្វើឱ្យធនធានធម្មជាតិមានភាពប្រសើរឡើង***

*បណ្ដាផ្នែកដែលគេបានជ្រើសរើសនៅខាងក្រោម ត្រូវបានរៀបរៀងទៅតាមចំនួនអ្នកឆ្លើយពីច្រើនបំផុត រហូតដល់តិចបំផុត សម្រាប់ជម្រើសនីមួយៗ។*

- ពង្រឹងក្រុមនៅតាមមូលដ្ឋានដែលកំពុងតែធ្វើការគ្រប់គ្រងធនធានធម្មជាតិ ដូចជា ធនធាននេសាទ ព្រៃឈើ និងកសិកម្ម ជាដើម
- បង្កើនការគ្រប់គ្រងធនធានធម្មជាតិឱ្យកាន់តែប្រសើរ
- បង្កប់រាល់វិធានការបន្សាំ ឬសម្រាលការប្រែប្រួលអាកាសធាតុនៅតាមគោលនយោបាយអភិវឌ្ឍន៍គ្រប់ផ្នែក
- បង្កើនប្រសិទ្ធផលក្នុងការប្រើប្រាស់ធនធានទឹកឱ្យបានអតិបរមា និងកៀរគរកធនធានទឹកក្រៅប្រភពធម្មតាឱ្យបានកាន់តែច្រើន

- ប្រកាន់យកគោលនយោបាយបង្ការទុកជាមុនដើម្បីកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងដើម្បីត្រៀមលក្ខណៈលៃលកជាមួយផលប៉ះពាល់របស់គ្រោះមហន្តរាយ
- កែលម្អប្រព័ន្ធលូបង្ហូរទឹកនិងការគ្រប់គ្រងកាកសំណល់ ជាពិសេសនៅតាមតំបន់ទីក្រុង
- ពង្រឹងភាពធន់របស់ហេដ្ឋារចនាសម្ព័ន្ធ និងបណ្ដាញសម្រាប់សម្រាលផលប៉ះពាល់ពីគ្រោះមហន្តរាយ
- កែលម្អប្រព័ន្ធលូបង្ហូរទឹកនិងការគ្រប់គ្រងកាកសំណល់ ជាពិសេសនៅតាមតំបន់ទីក្រុង

*កែលម្អអភិបាលកិច្ចឱ្យកាន់តែមានភាពប្រសើរឡើង ពង្រឹងស្ថាប័ន និងលើកកម្ពស់ការចូលពាក់ព័ន្ធរបស់ពលរដ្ឋ*

*បណ្ដាផ្នែកដែលគេបានជ្រើសរើសនៅខាងក្រោម ត្រូវបានរៀបរៀងទៅតាមចំនួនអ្នកឆ្លើយពីច្រើនបំផុតរហូតដល់តិចបំផុត សម្រាប់ជម្រើសនីមួយៗ។*

- ជំរុញលើកទឹកចិត្តឱ្យមានភាពជាដៃគូរវាងរដ្ឋាភិបាល សង្គមស៊ីវិល និងផ្នែកឯកជន នៅក្នុងការផ្ដល់សេវានានា
- ពង្រឹងប្រព័ន្ធសម្រាប់ការផ្ដល់សេវាសាធារណៈ ដើម្បីឆ្លើយតបទៅនឹងមតិយោបល់របស់ពលរដ្ឋអំពីគុណភាពសេវា
- ផ្ដល់លទ្ធភាពថែមទៀតដល់ពលរដ្ឋក្នុងការបញ្ចេញទស្សនៈរបស់ខ្លួនទៅលើការរៀបចំតាក់តែង និងការអនុវត្តកម្មវិធីនានារបស់រដ្ឋាភិបាល
- ផ្ទេរការទទួលខុសត្រូវពីថ្នាក់ជាតិទៅថ្នាក់ក្រោមជាតិ ( ឧ. ថ្នាក់ស្រុក ) ដើម្បីពង្រឹងពង្រីកការឆ្លើយតបទៅនឹងសេចក្ដីត្រូវការរបស់ពលរដ្ឋ
- ពង្រឹងក្របខណ្ឌគណនេយ្យភាពទូទៅក្នុងរង្វង់រដ្ឋាភិបាល
- មានប្រព័ន្ធលទ្ធកម្មដែលមានតម្លាភាពកាន់តែខ្លាំងឡើង
- ពង្រីកលទ្ធភាពទទួលបានព័ត៌មានដើម្បីកែលម្អតម្លាភាពនៅក្នុងការប្រើប្រាស់មូលនិធិសាធារណៈ [1, (1)]

*តើក្រុមធនាគារពិភពលោកអាចបញ្ចូលតួអង្គពាក់ព័ន្ធ ( ឧ. យុវជន សង្គមស៊ីវិល ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ពលរដ្ឋជាដើម ) បានដូចម្ដេចខ្លះ ឱ្យចូលពាក់ព័ន្ធនៅក្នុងការពិនិត្យតាមដានលើកម្មវិធីនានាដែលមានការគាំទ្រពីសំណាក់ក្រុមធនាគារពិភពលោក ?*

*មតិរបស់អ្នកឆ្លើយត្រូវបានរៀបរៀងទៅខាងក្រោម ដោយគ្មានលំដាប់លំដោយជាក់លាក់ទេ៖*

- តាមរយៈការរៀបចំវេទិកាទៀងទាត់ ដោយមានការចូលរួមរបស់តួអង្គពាក់ព័ន្ធ មួយត្រីមាសម្ដង
- គួរមានរបាយការណ៍ពិនិត្យតាមដានប្រចាំត្រីមាសសម្រាប់សាធារណជនអាន
- ការពិនិត្យតាមដានអនឡាញ ឬវេទិកាអនឡាញសម្រាប់ សម្រាប់កម្មវិធីដែលទទួលការគាំទ្រពីក្រុមធនាគារពិភពលោក ទទួលបានមតិជាតុចូលពីសាធារណជន

- យុទ្ធនាការទៀងទាត់តាមប្រព័ន្ធផ្សព្វផ្សាយដើម្បីលើកកម្ពស់ការយល់ដឹង នឹងធ្វើការពិនិត្យតាមដានវឌ្ឍនភាពរបស់គម្រោងនានា
- ធ្វើការពាក់ព័ន្ធជាមួយតួអង្គពាក់ព័ន្ធនៅពេញវដ្តអនុវត្តន៍របស់គម្រោង ឬកម្មវិធីនីមួយៗ ដោយសង្កត់ធ្ងន់លើគោលការណ៍នីតិរដ្ឋ
- ការកសាងសមត្ថភាពយុវជនលើផ្នែកបច្ចេកវិទ្យា
- បង្កើតយន្តការដែលងាយស្រួលសម្រាប់សាធារណជនរាយការណ៍តាមលេខទូរសព្ទ ឬគណនីហ្វេសប៊ុកដើម្បីគេអាចចែករំលែកអត្ថបទ ឬរូបថតបាន
- ក្រុមធនាគារពិភពលោកអាចធ្វើការជាមួយយុវជនដើម្បីបង្កើតគំនិតថ្មីៗទាក់ទិនទៅនឹងការជួយដល់សហគមន៍របស់គេ (ឧ. សំណើអំពីផលិតផលដើម្បីជួយកសិករឱ្យរក្សាបានរក្សាបានរំហូរប្រាក់ចំណូលបានរហូត)
- រក្សាទំនាក់ទំនងជាមួយប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន
- ធ្វើការពិគ្រោះយោបល់ជាលក្ខណៈឯករាជ្យជាមួយក្រុមផ្សេងតាមរយៈការធ្វើសម្ភាសន៍ស៊ីជម្រៅ
- បង្កើនកិច្ចសហការឱ្យច្រើនថែមទៀត